# ព្រះរាជជីវប្រវត្តិសង្ខេបរបស់អធិរាជខ្មែរ ព្រះបាទជ័យវរ្ម័នទី៧ មហាវីរៈក្សត្រខ្មែរល្បីល្បាញជាងគេបំផុត



ព្រះបាទជ័យវរ្ម័នទី៧ (Javarman VII) មានព្រះរាជមហេសី ២ព្រះអង្គ គឺព្រះនាងជ័យរាជទេវី និង ព្រះនាងឥន្ទ្រទេវី។ ព្រះមហេសីទាំងពីរព្រះអង្គ គឺជាបងប្អូនបង្កើត។ ព្រះនាងជ័យរាជាទេវី រៀបអភិសេកមុនពេលដែលព្រះបាទជ័យវរ្ម័នទី៧ បានឡើងសោយរាជ្យ។ ក្រោយពេលដែលព្រះនាងជ័យរាជាទេវី បានសោយទិវង្គតទៅ ទើបព្រះនាងឥន្ទ្រទេវី ដែលជាព្រះរៀម បានរៀបអភិសេកជាអគ្គមហេសីបន្ត។



ព្រះរាជជីវប្រវត្តិតាមសិលាចារឹក

ផ្ទាំងសិលាចារឹកដ៏ធំមួយនៃប្រាសាទព្រះខ័នស្ថិតនៅក្នុងខេត្តសៀមរាប ជាអតីតទីក្រុងខ្មែរមហាអស្ចារ្យរុងរឿង ដែលលោក គ្លែហ្សី បានប្រទះឃើញ គឺលោក ហ្សក សេដែស ជាជនជាតិបារាំងសែស ដែលបានបោះពុម្ពផ្សាយ កាលពីឆ្នាំ ១៩៤១។ ការផ្សព្វផ្សាយនូវទិន្នន័យដ៏សំខាន់បំផុត ពាក់ព័ន្ធទៅនឹងព្រះរាជជីវប្រវត្តិរបស់ព្រះបាទជយវរ្ម័នទី៧ ព្រះមហាវីរៈក្សត្រនៅសម័យមហានគរ។ មតិមហាជនខ្មែរមួយចំនួន មិនទាន់បានជ្រាបអំពីព័ត៌មានចម្បងទាំងនេះឲ្យបានច្បាស់លាស់នៅឡើយទេ។ ប៉ុន្តែអ្នកឯកទេសខាងប្រវត្តិសាស្ត្រកម្ពុជា បានលើកយកមកបកប្រែក្រៅផ្លូវការ ជូនជនរួមជាតិខ្មែរទុកជាចំណេះដឹងទូទៅខាងប្រវត្តិសាស្ត្រមួយកម្រិតទៀត។ គួររំលឹកផងដែរថា សិលាចារឹកនេះ (k-៩០៨) មានចារជាអក្សរទាំងអស់ចំនួន ១១១គាថា។ បណ្ឌិតបុរាណវិទូខ្មែរលោក មីសែល ត្រាណេ បានលើកឡើងថា ១៨ គាថាដើមនៃសិលាចារឹកនេះ មានលក្ខណៈដូចគ្នាបេះបិទទៅនឹងខ្លឹមសារនៃសិលាចារឹកប្រាសាទតាព្រហ្ម។ លោកបណ្ឌិតបានធ្វើការបកប្រែនូវគាថាមួយចំនួន ជាពិសេសគាថាជីវប្រវត្តិរបស់ព្រះបាទជ័យវរ្ម័នទី៧ ដូចតទៅនេះ៖

«ជាព្រះរាជាមួយព្រះអង្គ ដែលត្រូវបានព្រះរាជាទាំងពួង នៃដែនដីដែលនៅដៃមានកាន់យ៉ាងណែន មនុស្សគោរពសក្ការៈ។ ព្រះអង្គជាគតិបណ្ឌិតដ៏ឆ្នើមក្នុងចំណោមគតិបណ្ឌិតផងទាំងឡាយ ជាព្រះរាជបុត្រារបស់ព្រះ

រាជា ព្រះបាទស្រុតវរ្ម័ន និងព្រះបាទស្រីស្រេស្ថវរ្ម័ន ជាមនុស្សល្អប្រពៃ តាមរយៈព្រះសម្មិទ្ធិដ៏រុងរឿងថ្កើងថ្កាន ជាប្រភពនៃវង្សក្សត្រដ៏បរិសុទ្ធ » (គាថាទី ៦) ។

«ព្រះអង្គជាព្រះអាទិត្យនៅលើមេឃា ដែលជាវង្សត្រកូលកម្ពុជា ដែលបានប្រសូតឡើងនៅលើភ្នំខាងកើតនៃជយាទិត្យបុរៈ។ ព្រះអង្គបានដាស់បេះដូងផ្កាឈូកនៃសព្វសត្វលោក ជាឃ្លាំងនៃភាពត្រចេះត្រចង់ ជាអធិរាជនៃស្រេស្ថបុរៈ » (គាថាទី ៧)។

«ប្រសូតឡើងក្នុងមហានគរនៃគ្រួសារខាងព្រះមាតា ដែលព្រះចន្ទចែងចាំងនូវកាំរស្មីព្រះកិត្តនាមល្អប្រពៃឥតខ្ចោះ ភ្លឺថ្លាដូចព្រះនាងលក្សី ព្រះនាងបាននាំមុខកំពូលស្ត្រីទាំងឡាយ (គឺព្រះរាជិនី) កម្ពុជរាជលក្សី » (គាថាទី ៨)។

«ស្វាមីនៃដែនដីឯភវបុរៈ ព្រះបាទភវវរ្ម័នទេវៈ ប្រកបដោយសម្រស់ដ៏ភ្លឺថ្លា ដែលនាំមកនូវមន្តស្នេហ៍ចំពោះព្រះរាជនគររបស់ទ្រង់ ពោរពេញទៅដោយទេពកោសល្យ ជាប្រភពកំណើតនៃរាជវង្សានុវង្ស ដូចអ្នកដែលបានប្រកបដោយកាំរស្មីអមតៈ។ ព្រះអង្គបានសម្រាលនូវភាពឈឺចុកចាប់របស់ប្រជានុរាស្ត្ររបស់ទ្រង់ » (គាថាទី ៩)។

«អ្នកដែលមានអាកប្បកិរិយាល្អ ភាពល្បីល្បាញ វីរភាព ដែលគេមិនអាចស្តីបន្ទោសអ្វីៗទាំងអស់បានឡើយ។ ហើយទ្រង់បានប្រសូតក្នុងត្រកូលរបស់អ្នកនោះ ព្រមទាំងបានបង្កើតនូវកិច្ចការសម្រាប់មនុស្សគ្រប់មជ្ឈដ្ឋាន ព្រះបាទស្រីហស៍វរ្ម័ន ជាអ្នកបំផ្លាញសេចក្តីរីករាយរបស់សត្រូវក្នុងចម្បាំង ហើយមានព្រះរាជសកម្មភាពដ៏ថ្លៃថ្លាដែលបានផ្សព្វផ្សាយចេញពីវាចាគ្រប់ទិសទី » (គាថាទី ១០)។

«តាមរយៈព្រះមហាក្សត្រ និងព្រះរាជមហេសីនេះ ព្រះនាងស្រីជ័យរាជចូឌាមនី បានមានកំណើតឡើង» ... «ប្រៀបទៅនឹងជាត្រីដែលបង្កើតឡើងដោយភាពរឹងប៉ឹង ដូចកមលា ដោយសោភ័ណភាព ដូចអរុណោទ័យ ដោយអាកប្បកិរិយាដែលមិនអាចស្តីបន្ទោសបានឡើយ ដូចបៃត្រីដែលបានចាប់កំណើតដោយសប្បុរសធម៌ » (គាថាទី ១១-១២)។

« បានសោយរាជសម្បត្តិ នៅឯស្រីមន្តយសោធរបុរៈ ព្រះមហាក្សត្រជយវរ្ម័នទេវៈ ក្រោយពីផ្តាញ់រលកនៃពួកសត្រូវ ព្រះអង្គបានបោះបង្គោលរហូតដល់សមុទ្រ បង្គោលនៃ ជ័យជម្នះគ្រប់ទិសទី ព្រះអង្គនិងបុព្វការីជនប្រថាប់នៅឯមហិធរបុរៈ » (គាថាទី ១៣) ។

« ព្រះរាជបុត្រីរបស់ព្រះបាទស្រីហស៍វរ្ម័ន បានឲ្យកំណើតទៅមហាបុរសមួយរូប គឺ ព្រះបាទជយវរ្ម័ន ទី ៧ ប្រកបដោយថាមពលចែងចាំងដូចភ្លើងក្រហមឆ្អៅ ប្រៀបដូចទៅនឹងព្រះនាងអទិតិ ដែលបានធ្វើឲ្យព្រាហ្ម៍សីក្លាយទៅជាស្តេចនៃពពួកទេវតា ដែលដោយសារការប្រណិប័តន៍ដ៏ល្អប្រពៃដើម្បីការការពារដែនដី បានសម្លាប់ពួកមេទ័ពបច្ចាមិត្ត » (គាថាទី ១៨)។

រួមសេចក្តីមកគ្មានអ្វីសង្ស័យឡើយ ព្រះបាទជយវរ្ម័នទី៧ ពិតជាវង្សមហាក្សត្រាខ្មែរយ៉ាងពិតប្រាកដ ដែលបាន តពូជពង្សពីព្រះមហាវីរក្សត្រនាសម័យនគរភ្នំ និងចេនឡា ដ៏មានមហិទ្ធិឫទ្ធិគួរឲ្យស្ញប់ស្ញែង ហើយព្រះអង្គក៏ជា មហាបុរសរដ្ឋ ដែលបានការពារដែនដីខ្មែរយើង ដោយមានការលះបង់ខ្ពស់រកអ្វីប្រៀបផ្ទឹមពុំបានឡើយ។



ស្នាមព្រះហស្តក្នុងការកសាងផ្លូវជាតិធំៗចំនួន ៥ ខ្សែក្នុងរជ្ជកាលព្រះអង្គ

មិនត្រឹមតែកសាងនូវមន្ទីរពេទ្យនិងធម្មសាលា ប្រាសាទច្រើនរាប់មិនអស់ទេ ក្នុងរជ្ជកាលព្រះអង្គ ព្រះបាទ ជយវរ្ម័នទី៧។ ទ្រង់បានកសាងផ្លូវជាតិធំៗចំនួន ៥ ខ្សែ សម្រាប់ការធ្វើដំណើរឆ្លងកាត់អាណាចក្រ។ លោក វង់ សុធារ៉ា សាស្ត្រាចារ្យសិលាចារឹកសាស្ត្រ និងប្រវត្តិសាស្ត្រខ្មែរ និងជាអនុប្រធានដេប៉ាតឺម៉ង់ប្រវត្តិវិទ្យានៃសាកល វិទ្យាល័យភូមិន្ទភ្នំពេញ បានមានប្រសាសន៍ឲ្យដឹងកាលពីពេលថ្មីៗនេះថា ក្នុងរជ្ជកាលព្រះអង្គ ព្រះមហាវីរក្សត្រ អង្គនេះបានទ្រង់កសាងផ្លូវគមនាគមន៍សំខាន់ៗ ចំនួន ៥ ខ្សែ។ ខ្សែទី១ ផ្លូវខាងលិច ចាប់ពីយសោធបុរៈ កាត់ភ្នំស្រុកតម្រង់ទៅស្ពកកក់ធំ និងបន្ទាយឆ្មារ។ ខ្សែទី២ ផ្លូវនៅប៉ែកពាយ័ព្យប្រទេស ពីយសោធបុរៈទៅ ប្រសាទពិមាយ។ ខ្សែទី៣ ផ្នែកខាងជើង (មិនដឹងច្បាស់) គេរៀបរាប់បែបជាផ្លូវវង់មួយ គឺចេញពីរាជធានីទៅ កាន់ទីក្រុងជ័យវតី ជ័យសិង្ហវតី ជ័យវីរតី ជ័យរាជគិរី ស្រីសុវីរបុរី មកដល់យសោធបុរៈវិញ។ ចំណែកខ្សែទី៤ ផ្លូវ ព្នំសាន ពីរាជធានីយសោធបុរៈទៅកាន់រាជធានីរបស់ចាម និងទី៥ ផ្លូវខាងកើត ពីយសោធបុរៈ ទំនងជា តម្រង់ទៅសម្បូរព្រៃគុក ដែលគេអាចឃើញដាននៃសំណង់ស្ពានបុរាណជាច្រើន តាមដងផ្លូវជាតិលេខ៦ ចាប់

ពីស្ពានបុរាណនៅកំពង់ក្តីរហូតដល់ដំដែក។ លោកសាស្ត្រាចារ្យ វង់ សុធារ៉ា បានបន្តឲ្យដឹងថា ការកសាងផ្លូវគមនាគមន៍ចំនួន៥ ខ្សែនេះ នៅតាមផ្លូវព្រះអង្គ បានកសាងធម្មសាលា និងភ្លើងបំភ្លឺចំនួន ១២១កន្លែង សម្រាប់ជាជម្រកសាធារណៈ ដល់អ្នកធ្វើដំណើរទូទៅ។ លោកបន្តថា ក្នុងសិលាចារឹកប្រាសាទព្រះខ័ន បានបន្តឲ្យដឹងថា តាមផ្លូវពាយ័ព្យ មានធម្មសាលាចំនួន ១៧ ផ្លូវខាងជើង មានធម្មសាលាចំនួន ១៤ និង មានភ្លើងផ្លូវវណ្ណសាន មានធម្មសាលាចំនួន ៥៧ រួមទាំងភ្លើងនិង១នៅសូរ្យបរិត គឺភ្នំជីសូរ១ នៅវិជយាទិត្យនិង ១ នៅកល្យានសិទ្ធកៈ ទំនងជាត្រូវនឹងស្រុករំដួល ខេត្តស្វាយរៀង ។ បន្ថែមពីនោះ ធម្មសាលាសល់ចំនួន ៣0 ដោយសារមិនមានអត្ថបទសិលាចារឹក ធម្មសាលាដែលនៅសល់ ទំនងជាសង់តាមផ្លូវខាងលិច និងខាងកើត តាមកឆរបញ្ជាក់របស់លោកសាស្ត្រាចារ្យ វង់ សុធារ៉ា ។ លោកបានបន្តថា ក្រៅពីនេះព្រះអង្គបានកសាងមន្ទីរពេទ្យដែលភាសាជំនាន់នោះហៅថា អារោគ្យសាលា មានចំនួន ១0២ កន្លែង ប្រកបដោយគ្រឿងតង្វាយដ៏ច្រើនអនេក សម្រាប់ផ្គត់ផ្គង់ជីវភាព និងសកម្មភាពនៅតាមមន្ទីរព្យាបាលនីមួយៗ ពេទ្យជំនាញ ពេទ្យជំនួយ អ្នកបុកថ្នាំ អ្នកដាំទឹក អ្នកបម្រើការផ្សេងៗ ដែលសរុបមានប្រមាណ ៩0 នាក់ សម្រាប់មន្ទីរពេទ្យនីមួយៗ។ លោកសាស្ត្រាចារ្យ វង់ សុវធារ៉ា បានបន្តដោយគូសបញ្ជាក់ថា « អ្នកជំងឺគ្រប់ឋានៈសង្គម អាចទទួលការព្យាបាលដោយគ្មានការរើសអើង » (សិលាចារឹកសាយហ្វុង លេខ K ៣៦៨)។ លោកបន្ថែមថា ដោយសារព្រះអង្គយកចិត្តទុកដាក់លើសុខុមាលភាពនេះ ហើយដែលរហូតធ្វើឲ្យអ្នកស្រាវជ្រាវខ្លះសង្ស័យថា ព្រះអង្គកើតឃ្លង់ ដោយអ្នកស្រាវជ្រាវទាំងនោះ គ្រាន់តែពឹងផ្អែកលើការបកស្រាយរូបចម្លាក់នៅលើជញ្ជាំងប្រាសាទបាយ័ន និងរឿងព្រេងនិទានស្តេចគម្លង់ ដែលគេប្រឌិតឡើង នៅពេលក្រោយប៉ុណ្ណោះទេ។

អំពីព្រះបាទជ័យវរ្ម័នទី៧ (ព្រះរាជាដ៏មានមហិទ្ធិឫទ្ធិ និងព្រះរាជវង្ស)

ព្រះបាទជ័យវរ្ម័នទី៧ ជាព្រះរាជាដ៏មានមហិទ្ធិឫទ្ធិខ្លាំងពូកែចុងក្រោយនៃរាជាណាចក្រអង្គរ។ អ្នកប្រវត្តិសាស្ត្រអំពីប្រទេសកម្ពុជា លោក អៃម៉ូនីញ៉េរ៍ (Aymonier) បានសិក្សាពីព្រះបាទជ័យវរ្ម័នទី៧ និងសន្និដ្ឋានថា ជាក្សត្របង្កើតសម័យដ៏រុងរឿងបំផុតនៃប្រទេសកម្ពុជា។ ការបង្រួបបង្រួមជាតិរបស់ព្រះបាទជ័យវរ្ម័នទី៧ បានចាប់ផ្តើមចុះផ្សាយនៅក្នុងព្រឹត្តិបត្រ សាលាបារាំងចុងបូព៌ា ដោយសារលោក ល្វីស៍ ហ្វីណូត៍ (Louis Finot) នូវអត្ថបទសិលាចារឹកសំស្រ្កឹតមួយ ដែលប្រទះឃើញដោយលោក ហ្ស៊ក ម៉ាស្ប៉េរ៉ូ (Georges Maspero) នៅត្រង់សាយហ្វុង (Say Fong) ជិតក្រុងវៀងចន្ទន៍ ដែលផ្តល់ព័ត៌មានពីការកសាងមន្ទីរពេទ្យនៅ គ.ស ១១៨៦។ លោក ល្វីស៍ ហ្វីណូត៍ (Louis Finot) បានកត់សម្គាល់ថា សិលាចារឹកនេះមានន័យដូចសិលាចារឹក នៅសសរស្តម្ភ ដែលគេបានរកឃើញនៅឈូងសមុទ្រសៀម ជិតព្រំដែនកូសាំងស៊ីន (កម្ពុជាក្រោម) ហើយព្រះនាម ព្រះបាទជ័យវរ្ម័នទី៧ ត្រូវបានរំឭកជាញឹកញាប់ នៅក្នុងសិលាចារឹកចាមថា ជាអ្នកចម្បាំងមួយយ៉ាងធំធេង និងអស្ចារ្យ។ លោកបានសន្និដ្ឋានថា « សិលាចារឹកដែលមានចាប់ពីប្រទេសលាវខាងក្រោម ទៅឆ្នេរសមុទ្រអណ្ណាមនិងទៅទឹកដីកូសាំងស៊ីនខាងក្រោមខ្លះ បានរៀបរាប់ពីជោគជ័យរបស់ព្រះអង្គ ខ្លះទៀតអំពីអំពើល្អរបស់ព្រះអង្គ។ ទាំងនេះបានបំភ្លឺពីរូបភាពនៃព្រះមហាក្សត្រអង្គនេះពីក្នុងភាពងងឹតនៃអតីតកាលរបស់ប្រទេសកម្ពុជា » ។




ភាពងងឹតក៏បានរសាយដោយ សារការអត់ធ្មត់ក្នុងការស្រាវជ្រាវរយៈពេល ៤0ឆ្នាំ របស់លោក ល្វីស៍ ហ្វីណូត៍ ។ ព្រះនាមរបស់ស្តេចអង្គនេះ គេទើបនឹងបានស្គាល់នៅ គ.ស. ១៩00 ពេលគេបង្កើត សាលាបារាំងចុងបូព៌ា។ ឥឡូវនេះ គេចាត់ទុកព្រះអង្គជាព្រះមហាក្សត្រដ៏ខ្លាំងពូកែមួយអង្គ ក្នុងចំណោមព្រះមហាក្សត្រដ៏ខ្លាំងពូកែផ្សេងទៀតនៃប្រទេសកម្ពុជា។ ព្រះអង្គបានពង្រីកទឹកដីយ៉ាងធំបំផុតគិតទាំងប្រទេសចម្ប៉ាផង និងកសាងប្រាសាទជាច្រើនពាសពេញប្រទេស។ សិលាចារឹកជាច្រើន ដែលព្រះអង្គបានបន្សល់ទុកមានសិលាចារឹកបិតី

សិលាចារឹកតាព្រហ្ម ព្រះខ័ន និង បន្ទាយឆ្មារ ដែលព្រឹត្តិបត្រនៃសាលាបារាំងចុងបូព៌ា (Bulletin de L’École française d’Extrême-Orient) បានបោះពុម្ពផ្សាយ។ បទបញ្ញត្តិនៃមន្ទីរពេទ្យ ក្នុងសិលាចារឹកនៅផ្នែកខាងក្រោម មកពីប្រាសាទភិមានអាកាស ដែលគេបានប្រទះឃើញ នៅ គ.ស. ១៩១៦ ក្នុងព្រះបរមរាជវាំងអង្គរធំ និងសិលាចារឹកចាមមួយនៅមីសឺន (Mỹ-Sơn) គឺលោក ល្វី ហ្វីណូត៍ បានបោះពុម្ពនៅក្នុងព្រឹត្តិបត្រនៃសាលាបារាំង។ ព្រះបាទជ័យវរ្ម័នទី៧ ខ្លាំងពូកែដូចព្រះមហាក្សត្របារាំងសែសព្រះនាម ល្វីទី៧ (Louis VII) និង ហ្វីលីព្ហ អូហ្គុស្ត (Philippe Auguste) ដែលរជ្ជកាលរបស់ព្រះអង្គស្ថិតនៅក្នុងសម័យជាមួយគ្នា។

ព្រះរាជពង្សាវតាររបស់ព្រះអង្គ ត្រូវបានគេស្គាល់យ៉ាងច្បាស់លាស់។ ព្រះវររាជបិតារបស់ព្រះអង្គ សោយរាជ្យរយៈពេលយ៉ាងខ្លីក្នុងរវាង គ.ស. ១១៥៥។ ព្រះអង្គម្ចាស់ជ័យវរ្ម័នទី៧ ត្រូវជាបងប្អូនជីទួតមួយនឹង ព្រះបាទសូរ្យវរ្ម័នទី២ ដែលទ្រង់បានធ្វើសង្គ្រាមរហូតដល់តុងកឹង និងកសាងប្រាសាទអង្គរវត្ត ជាប្រាសាទចេតិយរបស់ព្រះអង្គ។ ព្រះវររាជមាតារបស់ព្រះអង្គ ជាប់សាលោហិតទៅនឹងព្រះសន្តតិវង្សពីបរទេស ដែលគ្រប់គ្រងប្រទេសជិតពេញស.វ.ទី១១ និងព្រះរាជិនីកម្ពុជាសម័យបុរេអង្គរ។ ព្រះអង្គម្ចាស់ជ័យវរ្ម័នប្រសូតនៅរវាង គ.ស. ១១២0 ឬយ៉ាងយូរណាស់ គ.ស. ១១២៥ ក្នុងរជ្ជកាល ព្រះបាទសូរ្យវរ្ម័នទី២ ហើយព្រះអង្គបានរៀបអភិសេកពីក្មេងបន្តិចជាមួយក្សត្រីជ័យរាជទេវី ដែលព្រះនាងមានឥទ្ធិពលខ្លាំងទៅលើព្រះអង្គក្នុងការគ្រប់គ្រងប្រទេស។

ក្រោយមក ព្រះអង្គត្រូវបញ្ជាឲ្យលើកទ័ព ទៅវាយប្រទេសចាម្ប៉ានៅតំបន់វិជ័យ (បច្ចុប្បន្នខេត្តប៊ិញឌិញ ប្រទេសវៀតណាម)។ អវត្តមាននៃព្រះស្វាមីបានធ្វើឲ្យព្រះនាងជយរាជទេវីធ្លាក់ព្រះកាយទៅក្នុងអន្លង់ទុក្ខសោក ដែលសិលាចារឹកនៃ ព្រះបរមរាជវាំង សរសេរដោយព្រះនាងឥន្ទ្រទេវី ត្រូវជាបងបង្កើតរបស់ព្រះនាង។ សិលាចារឹកបានរៀបរាប់ថា ព្រះនាងស្ថិតនៅអន្លង់ជ្រោះទឹកភ្នែក ទួញសោកប្រៀបដូចនាងសិតាព្រាត់ប្រាសពីព្រះស្វាមី ព្រះនាងសុំបន់ស្រន់សូមឲ្យព្រះស្វាមីវិលវិញ មធ្យោបាយបំភ្លេចទុក្ខសោកដ៏មហិមានេះ ព្រះនាងបានបួសជាបស្វិក្នុងព្រាហ្មណ៍សាសនា និង ក្រោយមកបួសក្នុងព្រះពុទ្ធសាសនា ។

ព្រះនាងឥន្ទ្រទេវី និង ព្រះនាងជ័យរាជទេវី ព្រះអគ្គមហេសីរបស់ព្រះបាទជ័យវរ្ម័នទី៧

សិលាចារឹកបានសរសេរថា « ទទួលការសិក្សាអប់រំពីបងស្រីបង្កើត ព្រះនាងគិតថា ព្រះពុទ្ធសាសនាជាទីស្រឡាញ់ពេញចិត្ត ព្រះនាងប្រកាន់យកមាគ៌ារបស់ព្រះពុទ្ធសាសនា ដែលជាមាគ៌ដ៏ស្ងប់ស្ងាត់ ដើម្បីឆ្លងកាត់ភ្លើងទុក្ខនិងសមុទ្រនៃសេចក្ដីឈឺចាប់ »។ នៅពេលដែលព្រះបាទជ័យវរ្ម័នទី៧ គង់នៅប្រទេសចាម្ប៉ា ព្រះបិតារបស់ព្រះអង្គគឺព្រះបាទធរណិន្ទ្រវរ្ម័នទី២ ទ្រង់ចូលទិវង្គត ហើយព្រះមហាក្សត្រដែលស្នងរាជ្យបន្តព្រះនាម យសោវរ្ម័នទី២ ដែលគេមិនស្គាល់ពីជីវប្រវត្តិ។ ក្នុងរជ្ជកាលរបស់ព្រះមហាក្សត្រអង្គនេះ មានព្រឹត្តិការណ៍សោកសៅមួយដែលមានចារនៅក្នុងសិលាចារឹក និងរូបចម្លាក់នៅប្រាសាទបន្ទាយឆ្មារ។ សិលាចារឹកនិងរូបចម្លាក់ប្រាសាទនេះ បានឲ្យដឹងថា ព្រះបាទយសោវរ្ម័នទី២ ត្រូវរាហុវាយលុកដូចពេលមុន សូរ្យគ្រាសឬចន្ទ្រគ្រាស តែបានយុវក្សត្រមួយអង្គជួយសង្គ្រោះ ទំនងជាព្រះរាជបុត្រណាមួយរបស់អនាគតព្រះបាទជ័យវរ្ម័ន ទី៧ ។

សិលាចារឹកសរសេរថា « នៅពេលដែលភរតរាហុបះបោរប្រឆាំងនឹងព្រះបាទយសោវរ្ម័ន ដើម្បីវាយលុកដណ្ដើមព្រះរាជវាំង កងទ័ពការពារទីក្រុង បានបាក់ទ័ពរត់អស់… ព្រះអង្គម្ចាស់ចូលប្រយុទ្ធ។ ទាហានពីរនាក់ បានចូល

រួមប្រយុទ្ធជាមួយព្រះអង្គ ហើយបានទទួលជ័យជម្នះលើភរតរាហុ » ។ ប៉ុន្តែ ព្រះបាទយសោវរ្ម័នទី២ បានត្រូវមន្ត្រីជាន់ខ្ពស់ម្នាក់ដណ្តើមរាជ្យ ដោយយកនាមថា ត្រីភូវនាទិត្យ នៅ គ.ស. ១១៦៥។ ព្រះអង្គម្ចាស់ជ័យវរ្ម័នទី៧ ក៏ប្រញាប់ប្រញាល់យាងត្រឡប់មកពីចាម្ប៉ា ដើម្បីជួយ សង្គ្រោះព្រះបាទយសោវរ្ម័នទី២។ សិលាចារឹកបានបន្តទៀតថា « ប៉ុន្តែព្រះបាទយសោវរ្ម័នទី២ ត្រូវអ្នកជ្រែករាជ្យធ្វើគុត ហើយព្រះអង្គម្ចាស់ជ័យវរ្ម័នទី៧ ក៏គង់នៅប្រទេសកម្ពុជា ដើម្បីរង់ចាំពេលវេលាល្អនឹងស្រោចស្រង់ស្ថានការណ៍វិញ ដែលពោរពេញទៅដោយអំពើឧក្រិដ្ឋ។ ព្រះអង្គម្ចាស់ក្សត្រី ដែលក្រៀមក្រំដោយទុក្ខពីព្រោះព្រះស្វាមីអវត្តមាន ក៏រលាយពីសេចក្តីទុក្ខព្រួយវិញ ដោយព្រះនាងចង់ឃើញព្រះអង្គរំដោះប្រទេសពីមហាសមុទ្រទុក្ខដែលបានលិចលង់នេះ »។ ព្រះអង្គម្ចាស់ជ័យវរ្ម័នទី៧ ដែលបានយាងត្រឡប់មកដល់ប្រទេសយឺតពេល និងបានឃើញអ្នកជ្រែករាជ្យនៅលើរាជបល្ល័ង្ក ព្រះអង្គក៏មិនទ្រង់យាងត្រឡប់ទៅចាម្ប៉ាវិញឡើយ និងដោយសារមានការជួយផ្តល់យោបល់ពីមហេសីផង ព្រះអង្គក៏គង់នៅកម្ពុជា « រង់ចាំពេលវេលាល្អសមស្រប »។ ព្រះអង្គត្រូវរង់ចាំអស់រយៈពេល ១៥ឆ្នាំ។ ក្នុងពេលជាមួយគ្នា ដែលនៅកម្ពុជាមានការជ្រែករាជ្យ នៅប្រទេសចាម្ប៉ាក៏មានការជ្រែករាជ្យដែរ នៅគ.ស. ១១៦៦-១១៦៧ ព្រះនាមជ័យឥន្ទ្រវរ្ម័ន។ ស្តេចអង្គនេះបានលើកសួយសារអាករទៅ ថ្វាយស្តេចអាណ្ណាម ព្រះនាមលី អាញ់តុន នៅគ.ស. ១១៧0 ដើម្បីឲ្យប្រទេសនេះស្ថិតនៅអព្យាក្រឹត ។

ក្នុងពេលនេះ ព្រំដែនខាងជើងនៃប្រទេសចម្ប៉ា ស្ថិតនៅក្នុងភាពស្ងប់ស្ងៀម ហើយស្តេចជ្រែករាជ្យចាម ក៏លើកទ័ពវាយលុកប្រទេសកម្ពុជា។ សិលាចារឹកភិមានអាកាសសរសេរទៀតថា « ព្រះបាទជ័យឥន្ទ្រវរ្ម័ន (ស្តេចចាម) ឥតកោតខ្លាចដូចក្រុងរាពណ៍នៅលើរថកាន់អាវុធវាយប្រយុទ្ធប្រទេសកម្ពុជា »។ ប៉ុន្តែ ការវាយលុកនេះពុំបានទទួលជោគជ័យទេ។ ស្តេចចាមនាមជ័យឥន្ទ្រវរ្ម័ន បានដូរយុទ្ធវិធីពីវាយតាមជើងគោក ទៅវាយតាមជើងទឹកវិញ។ នៅគ.ស. ១១៧៧ ស្តេចចាមអង្គនេះបានលើកទ័ពជើងទឹកចូលវាយខ្មែរ ដោយមានចិនលិចសំពៅម្នាក់ជួយនាំផ្លូវ។ ទ័ពនោះបានចូលតាមទន្លេមេគង្គ ហើយឡើងរហូតដល់បឹងទន្លេសាប។ ក្រុងអង្គរត្រូវធ្លាក់ក្នុងកណ្តាប់ដៃចាម ហើយស្តេចជ្រែករាជ្យត្រីភូវនាទិត្យវរ្ម័ន ក៏ត្រូវធ្វើគត់ក្នុងសមរភូមិ។ កងទ័ពចាមក៏ចូលកាន់កាប់ទីក្រុង ហើយបំផ្លិចបំផ្លាញនិងប្រមូលទ្រព្យសម្បត្តិយ៉ាងសន្ធឹកសន្ធាប់អស់ពីទីក្រុង។ ព្រះរាជបល្ល័ង្កត្រូវនៅទំនេរ គ្មានព្រះមហាក្សត្រសោយរាជ្យ។ ព្រះអង្គម្ចាស់ជ័យវរ្ម័នទី៧ ឃើញយល់ថា នេះពេលវេលាល្អបានមកដល់ហើយ ប៉ុន្តែមុននឹងប្រកាសជាស្តេចសោយរាជ្យ ព្រះអង្គត្រូវរំដោះប្រទេសចេញពីការគ្រប់គ្រងរបស់បរទេសសិន។ ព្រះអង្គក៏បានលើកទ័ពដេញកម្ចាត់ពួកចាមតាមជើងទឹក ដូចដែលមានរូបចម្លាក់នៅលើជញ្ជាំងប្រាសាទបាយ័ន និងប្រាសាទបន្ទាយឆ្មារ ហើយបានរំដោះប្រទេសទាំងមូល។ បួនឆ្នាំក្រោយការឈ្លានពានរបស់ចាមនៅគ.ស. ១១៧៧ នៅ គ.ស. ១១៨១ ប្រទេសកម្ពុជាបានសុខសន្តិភាព ហើយព្រះអង្គព្រះបាទជ័យវរ្ម័នទី៧ ក៏ប្រកាសឡើងគ្រងរាជ្យសម្បត្តិ។ នៅក្នុងពេលជាមួយនោះ ព្រះអង្គបានកសាងរាជធានីឡើងវិញ។ « ទីក្រុងយសោធបុរៈ ដូចជាស្រីក្រមុំម្នាក់ក្នុងត្រកូលខ្ពង់ខ្ពស់ បានផ្សំផ្គុំជាមួយ គូដណ្តឹងរបស់ខ្លួនក្នុងតណ្ហា ដែលពុះកញ្ជ្រោលលម្អទៅដោយរាជវាំងអំពីត្បូងមានតម្លៃ និងគ្របដណ្តប់ទៅដោយកំផែងដ៏រាំងមាំគឺក្រុងអង្គរ។ គូស្វាមីភរិយានេះ បានធ្វើពិធីអាពាហ៍ពិពាហ៍ដោយព្រះរាជា ដើម្បីបង្កើតសុភមង្គលនៃសត្វលោកក្រោមជ័យជម្នះដ៏ធំធេង ដែលព្រះអង្គដណ្តើមយកបាន » ។ សិលាចារឹកមួយនៅជ្រុងកំពែង អង្គរធំ បានសរសេរថា រាជបុរីដែលព្រះរាជារៀបពិធីអភិសេកនោះ គ្មានអ្វីក្រៅពីទីក្រុងអង្គរធំទេ ពុំមែនប្រាសាទបាខែង

នៅចុង ស.វ.ទី៩ ឡើយ។ តែជាទីក្រុងបច្ចុប្បន្ន ដែលមជ្ឈមណ្ឌលជាប្រាសាទបាយ័ន។ ក្នុងពេលដែលចាមចូលលុកលុយប្រទេសនាគ.ស. ១១៧៧ តាមអ្នកប្រវត្តិសាស្រ្តចិនឈ្មោះ ម៉ា ទួនលិន ថាព្រះបាទជ័យវរ្ម័នទី៧ « បានសច្ចាថានឹងសងសឹកសត្រូវរបស់ព្រះអង្គ ហើយកិច្ចការនេះ អត់ទ្រាំដោយស្ងាត់កំបាំងរយៈពេល ១៥ឆ្នាំ » ។ ប៉ុន្តែមុននឹងសម្រេចសេចក្តីសច្ចារបស់ព្រះអង្គ ដើម្បីធ្វើសង្គ្រាមនឹងចាមនៅក្នុងប្រទេស ព្រះអង្គត្រូវបង្ក្រាបការបះបោរនៅផ្នែកខាងត្បូងនៃទឹកដីបាត់ដំបង។ ដើម្បីបង្ក្រាបការបះបោរនេះ ព្រះអង្គបានបញ្ជា ក្សត្រចាមមួយអង្គនាម វិទ្យានន្ទន៍ ឲ្យលើកទ័ពទៅបង្ក្រាបបានរាបទាបឡើងវិញ។ គួរបញ្ជាក់ថា ក្សត្រចាមនេះបានមករស់នៅជាមួយព្រះអង្គតាំងពីក្មេងម្ល៉េះ សិលាចារឹកចាមនៅមីសឺន បានសរសេរថា « កាលពីកុមារភាពរបស់ព្រះអង្គ នៅគ.ស. ១១៨២ ព្រះអង្គម្ចាស់វិទ្យានន្ទន៍ បានយាងមកគង់នៅប្រទេសកម្ពុជា។ ព្រះមហាក្សត្រប្រទេសកម្ពុជា (គឺព្រះបាទជ័យវរ្ម័នទី ៧ បានឡើងសោយរាជ្យឆ្នាំមុន) បានទតឃើញលក្ខណៈ ៣៣ យ៉ាងរបស់ព្រះអង្គម្ចាស់។ ក៏មានព្រះទ័យស្រឡាញ់សព្វព្រះរាជហឫទ័យ ហើយព្រះអង្គបង្រៀនវិទ្យាសាស្រ្ត និងក្បួនយុទ្ធសាស្រ្តដល់ព្រះអង្គម្ចាស់នេះ។ នៅពេលដែលព្រះអង្គម្ចាស់គង់នៅប្រទេសកម្ពុជា រាជាណាចក្រនេះមានតំបន់មួយឈ្មោះ មល្យង ដែលមានមនុស្សអាក្រក់រស់នៅ ហើយបានងើបបះបោរឡើង ប្រឆាំងនឹងព្រះមហាក្សត្រខ្មែរ។ ព្រះរាជាបានទតឃើញព្រះអង្គម្ចាស់នេះពូកែខាងសឹកសង្គ្រាម ក៏បញ្ជាឲ្យដឹកនាំកងទ័ពខ្មែរ ដើម្បីទៅបង្ក្រាបការបះបោរ នៅមល្យងនេះបានទទួលជោគជ័យ។ ដោយសារគុណបំណាច់ ព្រះមហាក្សត្រខ្មែរទ្រង់ព្រះរាជទានកិត្តិយស និងទ្រព្យសម្បត្តិ ដែលមានតម្លៃខ្ពស់ៗដល់ទ្រង់វិទ្យានន្ទន៍ » ។



នៅ គ.ស. ១១៩០ ព្រះបាទជ័យវរ្ម័នទី៧ បានធ្វើឲ្យប្រទេសដាយវៀត (នៃមហារាជា លី កៅទន់) នៅអព្យាក្រឹត ដើម្បីឲ្យងាយស្រួលក្នុងការវាយចាម ក្នុងឆ្នាំដដែល ឱកាសល្អហុចឲ្យដោយស្តេច ចាមជ័យឥន្ទ្រវរ្ម័នទី៤ លើកកងទ័ពមកវាយខ្មែរម្តងទៀត។ តើព្រះបាទជយវរ្ម័នទី៧ ទ្រង់លើកទ័ពប្រឆាំងនឹងការវាយលុករបស់ចាមឬយ៉ាងណា? សិលាចារឹកនៅប៉ោនគរ (ឯញ៉ាត្រាង) បានសរសេរទុកថា « ព្រះអង្គវាយយកបានរាជធានីនៃប្រទេសចាម្ប៉ានិងប្រមូលយកលិង្គទាំងអស់ »។ ជោគជ័យនេះបាន ដោយសារព្រះអង្គបញ្ជាទ្រង់វិទ្យានន្ទន៍លើកទ័ពទៅ

ទប់ទល់។ ទ្រង់វិទ្យានន្ទន៍វាយយកបានក្រុងវិជ័យ (ប៊ិញឌិញ) ហើយចាប់ស្តេចចាមជ័យឥន្ទ្រវរ្ម័នទី៤ ជាឈ្លើយមកថ្វាយព្រះបាទជយវរ្ម័នទី៧។ ព្រះអង្គបានលើកព្រះអនុជថ្លៃរបស់ព្រះបាទជយវរ្ម័នទី៧ ព្រះនាម អិន (អនុជព្រះនាងជ័យរាជទេវី) ឲ្យឡើងសោយរាជ្យនៅវិជ័យ។ ដោយមានព្រះបរមនាមថា សូរ្យជ័យវម៍ទេវៈ រួចព្រះអង្គលើកទ័ពបង្ក្រួសទៅវាយយកបាណ្ឌុរង្គ (ផានរ៉ាង) ហើយឡើងសោយរាជ្យនៅទីនោះ ដោយមានព្រះរាជបរមនាមថា សូរ្យវម៍ទេវៈ ។ ប្រទេសចាម្ប៉ាបានចែកជាពីរផ្នែក មួយផ្នែកគ្រប់គ្រងដោយព្រះរាជាខ្មែរ និងមួយផ្នែកទៀតដោយក្សត្រចាម វិទ្យានន្ទន៍។ តែមិនយូរប៉ុន្មាន ពួកចាមនៅវិជ័យ ក៏ងើបបះឡើង ដោយបណ្តេញព្រះអង្គម្ចាស់ អិន រត់ចូលមកស្រុកខ្មែរវិញ ហើយលើកស្តេចចាម ព្រះនាម រសុបតិ ឲ្យឡើងសោយរាជ្យជាជំនួសវិញ។ ឆ្លៀតឱកាសនេះ ព្រះរាជាវិទ្យានន្ទន៍បានបង្រួបបង្រួមប្រទេសចាមឲ្យមានឯកភាពឡើងវិញ ក្រោយពីបានធ្វើគុតព្រះជ័យឥន្ទ្រវរ្ម័នទី៥ (រសុបតិ) ហើយឡើងសោយរាជ្យប្រទេសចាម្ប៉ាទាំងមូល ពីគ.ស. ១១៩២ ដល់ ១២០៣។ នៅ គ.ស. ១១៩៣ និង ១១៩៤ ព្រះបាទជ័យវរ្ម័នទី៧ ទ្រង់បានសាកល្បងឲ្យព្រះវិទ្យានន្ទន៍ទទួលស្គាល់អំណាចព្រះអង្គវិញ តែឥតប្រយោជន៍ទេ រហូតដល់ គ.ស. ១២០៣ ព្រះអង្គបានបញ្ជាស្តេចចាមមួយអង្គទៀត ព្រះនាមអុងធនបតិក្រាម ដែលត្រូវជាឪពុកមារបស់ទ្រង់វិទ្យានន្ទន៍ ឲ្យលើកទ័ពទៅវាយកម្ចាត់ក្មួយព្រះអង្គទាល់តែបាន។ ចាប់ពីគ.ស. ១២០៣ ដល់ ១២២០ ប្រទេសចាម្ប៉ាក៏ក្លាយទៅជាអាណាខេត្តរបស់ខ្មែរ។ ការលូកដៃច្របូកច្របល់នៅក្នុងប្រទេសខាងកើត ដែលជាប្រទេសជិតខាង ពុំបានទប់ស្កាត់មិនឲ្យព្រះអង្គ ពង្រីកទឹកដីទៅខាងជើង និងខាងលិចនៃប្រទេសកម្ពុជាឡើយ គឺនៅក្នុងរជ្ជកាលនេះហើយ ដែលសិលាចារឹកសាយហ្វុង (ជិតក្រុងវៀងចន្ទន៍) បានបញ្ជាក់ពីកាលបរិច្ឆេទ ហើយអ្នកប្រវត្តិសាស្ត្រចិន បាននិយាយពីអំណាចរបស់ព្រះបាទជ័យវរ្ម័នទី៧ បានភ្ជាប់ទឹកដីមួយផ្នែកនៃឧបទ្វីបមឡាយូ និងវាតអំណាចរហូតដល់ប្រទេសភូមា។ ម្យ៉ាងទៀតសិលាចារឹកមួយនៃប្រាសាទព្រះខ័ន បានឲ្យដឹងថា ទឹកមន្តត្រូវបានផ្តល់ ដោយព្រាហ្មណ៍សូរ្យភគ្គ និងព្រហ្មណ៍ឯទៀតទាំងអស់ក្នុងព្រះបរមរាជវាំង ព្រះរាជានៃយវនៈ និងព្រះរាជាពីរអង្គនៃប្រទេសចម្ប៉ា។ ព្រាហ្មណ៍សូរ្យភគ្គ ប្រហែលជាមេនៃព្រាហ្មណ៍ទាំងអស់ក្នុង ព្រះបរមរាជវាំង។ ព្រះរាជានៃយវនៈ គឺជាអធិរាជ លី អាញ់តុង (Lý Anh Tông) ដែលសោយរាជ្យនៅ គ.ស. ១១៧៥ មានព្រះបរមនាមសម្រាប់រាជ្យថា លីកាវតុង (Lý Cao Tông) និងសោយរាជ្យរហូតដល់ គ.ស. ១២១០។ ព្រះរាជាពីរអង្គនៃប្រទេសចម្ប៉ា គឺព្រះរាជាសោយរាជ្យនៅក្រុងវិជ័យ (ប៊ិញឌិញ) ដែលត្រូវជាព្រះអនុជថ្លៃនៃព្រះបាទជ័យវរ្ម័នទី៧ និងព្រះរាជាដែលសោយរាជ្យនៅបាណ្ឌុរង្គ (ផានរ៉ាង) គឺទ្រង់វិទ្យានន្ទន៍ ដែលការពារដោយព្រះជយវរ្ម័នទី៧។

គេបានដឹងថា ការថ្វាយទឹកមន្តមានន័យថា ទទួលស្គាល់ការស្ថិតនៅក្នុងចំណុះនៃប្រទេសដែលគេថ្វាយនោះ។ ទំនៀមនេះ នៅមានរហូតដល់សព្វថ្ងៃនេះ។ នៅក្នុងរាជវាំងក្រុងភ្នំពេញឬបាងកក នៅពេលពិធីអភិសេកស្តេចឡើងសោយរាជ្យ ទឹកមន្តសម្រាប់ធ្វើពិធី គឺជាទឹកដែលទទួលបានពីទន្លេសំខាន់ៗនៃប្រទេស និងពីខេត្តផ្សេងៗ នៃព្រះរាជាណាចក្រ។ ការស្ថិតនៅក្រោមចំណុះប្រទេសកម្ពុជា នៃប្រទេសចាម្ប៉ាទាំងពីរ មិនយូរអង្វែងដូចនៅក្រោមអំណាចរបស់ថ្ងៃ អំណាចរបស់មហារាជអណ្ណាមឡើយ។ ក្រោយពីព្រះនាងជ័យរាជទេវីសោយព្រះពិរាល័យទៅ ព្រះបាទជយវរ្ម័នទី៧ បានរៀបរាជាភិសេកជាមួយព្រះនាងឥន្ទ្រទេវី ដែលជាព្រះរៀមបង្កើតរបស់ព្រះនាងជយទេវី។ ក្សត្រីអង្គនេះជាស្ត្រីសម្បូរទៅដោយចំណេះវិជ្ជាជាច្រើន។ ព្រះនាងបានទទួលតំណែងជាសាស្ត្រាចារ្យក្នុងវត្តព្រះពុទ្ធសាសនាមួយ ហើយបានកសាងសិលាចារឹកភិមានអាកាស ដែលជាប្រភពយ៉ាង

សំខាន់ទាក់ទងនឹងព្រះជីវប្រវត្តិនៃព្រះបាទជ័យវរ្ម័នទី៧។ គេមិនដឹងច្បាស់ថា ព្រះបាទជយវរ្ម័នទី៧ សោយទិវង្គតទៅនៅឆ្នាំណាទេ។ ព្រះអង្គទំនងជាសោយរាជ្យរហូតដល់ គ.ស. ១២១៨។ ព្រះអង្គមានព្រះមរណនាមថា មហាបរមសៅគត។ ព្រះនាមនេះសឲ្យឃើញថា ព្រះអង្គជាពុទ្ធសាសនិកជនមួយរូប តែទោះបីយ៉ាងហ្នឹងក៏ដោយក៏ព្រះអង្គមានព្រាហ្មណ៍បុរោហិតមួយរូប ឈ្មោះ ឫសីកេស (ឫឞិកេឝ) ដែលជាសក្ខីភាពប្រាប់ថា សាសនាព្រាហ្មណ៍នៅពេលនោះ នៅមានឥទ្ធិពលខ្លាំងគួរសមដែរ។ តាមរូបបដិមាព្រះបាទជយវរ្ម័នទី៧ មានសាច់មាំព្រះកេសមានផ្នួងសក់តូច។ លក្ខណៈនេះមានច្បាស់នៅ លើក្បាច់ចម្លាក់ជាច្រើន គេបានឃើញរូបបដិមាពីរ គឺមួយនៅអង្គរធំ និងមួយទៀតនៅប្រាសាទ ពិមាយជិតគោរាជ (โคราช ខូរ៉ាត) (នគររាជ) ដែលថែរក្សានៅសារមន្ទីរក្រុងបាងកក។ រូបបដិមាទាំងពីរនេះ គឺជាព្រះរូបរបស់ ព្រះបាទជយវរ្ម័ន ទី៧។

អំពីកាលបរិច្ឆេទនៃការសោយទិវង្គត គេពុំបានដឹងពិតប្រាកដទេ។ គេចោទជាសំណួរថា តើព្រះអង្គមានព្រះរោគអ្វី ដែលនាំឲ្យព្រះអង្គសោយទិវង្គត? មានរូបចម្លាក់ពីរនាសម័យនោះ គឺរូបចម្លាក់ នៅហោជាងប្រាសាទតូច ដែលគេហៅថា មន្ទីរពេទ្យ ស្ថិតនៅខាងកើតប្រាសាទតាកែវ។ លោក វិកទរ ហ្គោលូបេវ (V. Goloubew) បានសិក្សាយ៉ាងល្អិតល្អន់លើក្បាច់ចម្លាក់ ដើម្បីស្វែងយល់អំពីរឿង « ស្តេចគម្លង់ » ប៉ុន្តែពុំមានរូបបដិមាណាដែលត្រូវនឹងរឿងនេះឡើយ។ ហើយលោកបានផ្តល់អត្ថបទរបស់លោកវេជ្ជបណ្ឌិត ម៉េស៍ណារដ៍ (Mesnard) ជានាយកវិទ្យាស្ថានប៉ាស្ទ័រ នៅក្រុងព្រៃនគរ បានប្រគល់ឲ្យគាត់ នៅ គ.ស. ១៩៣៤ អំពីអត្ថាធិប្បាយលើក្បាច់ចម្លាក់នៃប្រាសាទបាយ័នដូចតទៅ ៖

« កំភួនដៃនិងដៃនៃអ្នកជំងឺ ជាវត្ថុបំណងនៃការព្យាបាលយ៉ាងយកចិត្តទុកដាក់ ពីស្ត្រីដែលនៅព័ទ្ធជុំវិញ។ កាយវិការនៃស្ត្រីម្នាក់ មានលក្ខណៈដូចជាចាប់កាន់ត្រចៀកខាងស្តាំបើកឲ្យធំ ដើម្បីឲ្យគេចាប់អារម្មណ៍ទៅលើចំណុចដែលសំខាន់បំផុត »។ « អវយវៈក្រោម ទ្រដោយវត្ថុមួយនៅក្រោមជង្គង់ »។ « ស្ត្រីម្នាក់លើកជើងស្តាំរបស់មនុស្សនោះ ដោយដៃឆ្វេង និងដៃស្តាំដូចជារឹតច្របាច់គក់ជើងឆ្វេង »។ « កាយវិការនៃស្ត្រីទាំងនេះ ដូចជាចង្អុលបង្ហាញថា មនុស្សនោះមានជំងឺនៅចុងអវយវៈគឺជំងឺឃ្លង់?» ការកត់ចំណាំសំខាន់មួយទៀតនៅជិតខ្លួននៃមនុស្សនោះមានថូមួយ ដែលដាក់ផ្លែឈើរាងមូលពេញ។ ផ្លែឈើនេះប្រហែលជាផ្លែក្របៅ (Chaulmoogra) ។ ដើមក្របៅ (Hydnocarpus anthelmintica) ជាដើមឈើ ដែលដុះពាសពេញព្រៃ៕

ប្រភព៖ មនោវិទ្យា